www.khmerpostusa.com

សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា

# KhmerPost USA

Lowell - Lynn - Revere - MA * Providence - Cranston - RI

Free Copies

Vol. 13. Issue #298
Aug 13Th, 2020
Office: 978-677-7163
Direct: 978-656-8141
Email:Khmerpostusa@gmail.com

## ព័ត៌មានសំខាន់ៗខាងក្នុង...

ប្រធានគណបក្សខ្មែរឈ្នះត្រូវបានសមត្ថកិច្ចចាប់ខ្លួន... សូមអាននៅទំព័រទី ០២




ហ៊ុន ម៉ាណែត ជានាយករដ្ឋមន្ត្រីកម្ពុជា សូមអាននៅទំព័រទី ០៥



ទីបំផុតតុលាការសម្រេចចេញដីការឃុំខ្លួនលោករ៉ុង ឈុន... សូមអាននៅទំព័រទី ០៦



កម្ពុជាត្រៀមថវិការជាង១ពាន់លានដុល្លារ សូមអាននៅទំព័រទី ០៩



# កាម្លា ហារីស Kamala Harris ត្រូវបាន ជោ បាយដិន យកជាដៃគូរ



លោក ជោ បាយដិន        លោកស្រី កាម្លា ហារីស

ដោយ ពិន សំខុន

បេក្ខជនប្រធានាធិបតីខាងគណបក្សប្រជាធិបតេយ្យ ជោ បាយដិន ទើបនឹងបានជ្រើសយកដៃគូរខ្លួន កាលពីម្សិលមិញ គឺ កាម្លា ហារីស ដែលធ្វើឱ្យមានការភ្ញាក់ផ្អើលជាខ្លាំង ពីព្រោះជាស្ត្រីភេទស្បែកខ្មៅ មានម្ដាយជាតិឥណ្ឌា(អាស៊ី)នឹងឪពុកជាតិ"យាម៉ាអ៊ីកាំង" (ហារីសមានសញ្ជាតិអាស៊ាន.អាមេរីកាំង) ហើយខាងគណបក្សប្រជាធិបតេយ្យទទួលការអបអរសាទរ ដោយសារជាស្ត្រីដែលមានបទពិសោធន៏មានសមត្ថភាពនឹងមានស្មារតីរឹងមាំ។ បាយដេននឹងហារីស ត្រូវទៅប្រកួតជាមួយ ត្រាំនឹងផែន នៅថ្ងៃ៣វិច្ឆិកា ២០ខាងមុខ។

ប៉ុន្តែ ហារីស មិនជាទីរាប់អានសម្រាប់គណបក្សសាធារណរដ្ឋរបស់បេក្ខជន ឌុណល ត្រាំ នោះទេ។ លោក ត្រាំ បានផ្ដើមទិទៀនថា "ហារីស មាននយោបាយឆ្វេងផុត នឹងនិយាយគ្មានបានការ" គេចង់និយាយថា មានទំនោរទៅខាងកុម្មុយនិស្ត ប៉ុន្តែអ្នកវិភាគព័ត៌មានទូទៅ គេយល់ថា "កាម្លា ហារីស នឹងក្លាយទៅជាគូរប្រកួតចំបងរបស់លោក ត្រាំ នៅថ្ងៃខាងមុខនឹងមិនមែនជា ជោ បាយដិន នោះទេ"។

ក្នុងខែសីហានេះ បេក្ខជនប្រធានាធិបតីត្រូវឆ្លងកាត់វិញ្ញាសារ"សន្និបាទតែងតាំងបេក្ខជនប្រធានាធិបតី"... ដែលនឹងត្រូវធ្វើ ដោយមិនមានការរួមប្រជុំសមាជិក ដូចពេលមុនៗនោះទេ ហើយនៅសល់មិនដល់៣ខែទេ ដែលការប្រកួតផ្ដាច់ព្រ័ត្រក៏នឹងមកដល់ដែរ ។ ពេលនេះ ការស្ទង់មតិសាធារណៈបានឱ្យលោកឌុណល ត្រាំ ចាញ់ ជោ បាយដិន **តទៅទំព័រទី ១២**



មេធាវី លុយ ហាស្កែល LAW OFFICE OF LOUIS S. HASKELL

សេវាកម្មជាទីគាប់ចិត្តចាប់តាំងពីឆ្នាំ 1987

គ្រោះថ្នាក់ចរាចររថយន្តធុនតូច, រថយន្តធុនធំ និងម៉ូតូ • អន្តោប្រវេសន៍
ធ្វើពន្ធ • ការក្ស័យធន • គ្រោះថ្នាក់រអិលដួល • ឆ្កែខាំ
ដំណោះស្រាយ និងការពារបញ្ហាពន្ធដា

សូមអរគុណចំពោះការបន្តទុកចិត្តរបស់លោកអ្នកមកលើការិយាល័យមេធាវីយើងខ្ញុំ ក្នុងការដោះស្រាយបញ្ហាផ្នែកច្បាប់ និងពន្ធដារជូនលោកអ្នក ។ យើងខ្ញុំរំពឹងថា នឹងបានបម្រើលោកអ្នកយ៉ាងល្អនាពេលអនាគត។

បុគ្គលិកយើងខ្ញុំនិយាយភាសាខ្មែរ

Excellent Service Since 1987

Auto, Truck and Motorcycle Accidents
Immigration • Tax • Bankruptcy
Slip & Fall • Dog Bite
Tax Resolution & Defense

*Thank you for your continued confidence*
*In our office to handle your legal and tax matters.*
*We look forward to serving you well into the future.*

LAW OFFICE OF LOUIS S. HASKELL • 16 PINE STREET • LOWELL, MA • (978) 459-8359

16 Pine Street • Lowell, MA • 978-459-8359 • www.attorneyhaskell.com

# បោះឆ្នោតថ្ងៃទី១កញ្ញា

ឬក៏ផ្ញើរសំបុត្រសន្លឹកឆ្នោត ឲ្យបានមុនថ្ងៃបោះឆ្នោត

**វណ្ណា ហាវើដ អាចនឹងក្លាយជា ស្ត្រីខ្មែរទី១ ដែលជាប់ឆ្នោត នៅរដ្ឋម៉ាសាឈូសិត**



### សុខាភិបាលសាធារណៈ

យើងត្រូវតែធានាសុវត្ថិភាព អ្នកដែលទន់ខ្សោយដែលនៅជុំវិញយើង មនុស្សចាស់ មនុស្សមានស្ថានភាពលំបាក សហគមន៍ពណ៌សម្បុរ ថែរទាំសុខភាពអ្នកធ្វើការ អ្នកឆ្លើយតបមុនគេ និងអ្នកធ្វើការចាំបាច់

### សេដ្ឋកិច្ចជាសះស្បើយ

អាទិភាពរបស់ខ្ញុំគឺជួយឲ្យមនុស្សត្រឡប់ទៅធ្វើការវិញដោយសុខសាន្ត ហើយនឹងកសាងសេដ្ឋកិច្ចក្នុងក្រុងឡើងវិញ។ ខ្ញុំនឹងប្រើចំណេះនិងបទពិសោធន៍ សេវាសាធារណៈរបស់ខ្ញុំ ទៅជួយសហគមន៍យើងឲ្យទទួលនូវការចាប់អារម្មណ៍ និងផ្តល់ថវិការដែលគេត្រូវការ

### វិស័យអប់រំនិងថែរទាំកុមារ

មាតាបិតា, និស្សិត, គ្រូបង្រៀន, បុគ្គលិក ត្រូវតែដឹងថា«យើងផ្តល់អាទិភាព ដល់សុខភាព ហើយធ្វើយ៉ាងណា កុំឲ្យទុកចោលនិស្សិតដែលទន់ខ្សោយ។ ខ្ញុំនឹងប្រយុទ្ធដើម្បីធានាថាច្បាប់ដែលផ្តល់សំណាងដល់និស្សិតឲ្យចូលជាធរមាន និងផ្តល់ថវិការឲ្យបានគ្រប់គ្រាន់

## VANNA HOWARD

STATE REPRESENTATIVE

17th Middlesex District

vannahoward.com

PAID FOR BY CTE VANNA HOWARD

# VOTE SEPTEMBER 1ST

OR VIA MAIL IN BALLOT BEFORE ELECTION DAY

**Vanna Howard would be the first Khmer woman elected to the Massachusetts State Legislature.**



### Public Health

We must ensure the safety of the most vulnerable among us - our seniors, people with underlying conditions, communities of color, health care workers, first responders, and essential workers.

### Economic Recovery

My priority is getting people safely back to work and rebuilding our local economy. I'll use my public service experience and skillset to help our communities get the attention and funding we deserve.

### Education and Child Care

Parents, students, teachers, and staff need to know that we're prioritizing health and making sure at risk students don't fall behind. I'll fight to ensure the Student Opportunity Act is implemented and fully funded.

## VANNA HOWARD

STATE REPRESENTATIVE

17th Middlesex District

vannahoward.com

PAID FOR BY CTE VANNA HOWARD

# ព្រះសង្ឃ ប៊ុត ប៊ុនតិញ ក៏សាងវត្ត“វត្តភ្នំសេរី”នៅអាមេរិក

ដោយ ពិន សំខុន

*ថ្ងៃទី៨សីហា ២០២០* នេះជាឈ្មោះវត្តខ្មែរថ្មីស្រឡាងមួយស្ថិតនៅចម្ងាយប្រមាណជាកន្លះម៉ោងខាងត្បូងឡូវែល ដែលគេនាំគ្នាសន្មត់ពេលនេះថា-វត្តភ្នំសេរី -មានព្រះតេជគុណ ប៊ុត ប៊ុនតិញ ជាអ្នកដឹកនាំ និងព្រះអង្គធ្លាប់ឱ្យដឹងថាព្រះអង្គជាស្ថាបនិករបស់ទូរទស្សន៍ព្រះអាទិត្យរបស់គណបក្សសង្គ្រោះជាតិផងដែរ ។

ថ្ងៃអាទិត្យ ទី៣ សីហា យើងបានចេញដំណើរទៅកាន់វត្តខ្មែរនោះជាមួយមិត្តសំឡាញ់ម្នាក់ឈ្មោះ ប៉ាន់ សូ ជាសាស្ត្រាចារ្យចូលនិវត្តន៍នៅឡូវែល វេលាម៉ោង១០ព្រឹក សំដៅទៅអស័យដ្ឋានវត្ត 111 FiChburg Rd.Ayer, MA 01432 ទម្រាំទៅដល់ទីដៅម៉ោង១០កន្លះទៅហើយ មនុស្សម្នាបានទៅដល់ច្រើនគ្នារួចជាស្រេច ខ្លះក៏បោសច្រាសសំអាតបរិវេណដែលសម្បូរដោយដើមឈើធំៗ ផ្តល់នូវម្លប់ត្រជាក់ ខ្យល់បក់ត្រសៀក គួរឱ្យចង់ចងអង្រឹងសម្រាកកាយមួយរំពេច, ខ្លះទៀតរៀបចំម្ហូបចំណី រួមទាំងបង្អែម ភេសជ្ជៈ ត្រជាក់ ដ៏ហូរហៀរ ហើយម្ហូបមួយចំនួនទៀតក៏មកដល់ជាបន្តបន្ទាប់ ។ ភាពញញឹមញញែមរីករាយដាក់គ្នាពេលប្រកបការងារបោសសំអាតទីធ្លា បរិវេណវត្តយ៉ាងសកម្មនឹងយ៉ាងសទ្ធា មុនពេលវេចង្ហាន់ត្រង់ប្រគេនលោក គួរឱ្យចង់ធ្វើអំពើបុណ្យនោះពេកណាស់ៗ នៅកណ្តាលទីធ្លាដ៏ធំទូលាយនោះ មានអាគារដែលនឹងក្លាយទៅជាព្រះវិហារទៅថ្ងៃក្រោយក៏ធំទូលាយ


ព្រះតេជគុណ ប៊ុត ប៊ុនតិញ

ណាស់ដែរ ក៏ប៉ុន្តែត្រូវការជួសជុលឡើងវិញទាំងអស់ ទើបអាចប្រើការបំរើព្រះពុទ្ធសាសនាបាន។ ទីធ្លាដីដ៏ធំទូលាយឋិតនៅទន្ទឹមនឹងអូរ ដែលមានទឹកហូរថ្លាឆ្វង់មួយជាកំណត់ព្រំដែនវត្ត, ព្រះតេជគុណ ប៊ុត ប៊ុនតិញ បានឱ្យដឹងថា លោកមិនបានគង់នៅទីនោះទេ ពេលនេះលោកបានគង់នៅវត្តព្រះអង្គ មី ឡែម ជាបណ្តោះអាសន្ន ហើយតើពីព្រលឹមដើម្បីនិមន្តមកវត្ត ហើយធ្វើការចាំបាច់មុនគេជារៀងរាល់ព្រឹក។ គេកត់សំគាល់វត្តមានព្រះតេជគុណ មី ឡែម អតីតចៅអធិការវត្តត្រៃរតនារាមនឹងចំណុះជើងវត្តព្រះអង្គ ក៏បានមកជ្រោមជ្រែងកម្មវិធីនាថ្ងៃអាទិត្យទី៣នេះ ប្រកបដោយសទ្ធាជ្រះថ្លាដែរ។ ក្រៅពីនោះមានវត្តមានលោក ប៉ែន សុខដល អ្នកស្រី ស៊ូស៊ុ អ្នកស្រី ពៅ លោក ទុរី , មកដល់ក្រោយគេបន្តិច លោក អ៊ុង ឫទ្ធី អ្នកស្រី សុភា លោក ម៉ទីណុល ជាក្រុមឡូវែលរួមនឹងក្រុមភ្ញៀវមកពីតំបន់ជិតឆ្ងាយជាហូរហែរ រហូតដល់មានចំនួនប្រមាណជា៥០៦០នាក់ទៀត។ ពួកគេបានសន្យាគ្នាដូចដែលគេបានធ្វើកាលពីថ្ងៃសៅរ៍មុន១ថ្ងៃនេះ ថា-នឹងបន្តការជួបជុំគ្នារបៀបនេះទៀត រហូតដល់ទិសក្ការៈមួយនេះ មានការរៀបចំសមរម្យ ។

ម៉ោងជាង១១ហើយ លោក អាណ្យពូនី បានប្រកូកតាមឧឃោសនស័ព្ទឱ្យឧបាសក ឧបាសិកាបញ្ឈប់ការងារមកជួបជុំគ្នាដើម្បីប្រគេនចង្ហាន់ព្រះសង្ឃទាំង២អង្គនៅក្រោមម្លប់ឈើធំៗទាំងនោះៗ បន្ទាប់ពីសូត្រមន្តប្រទានពររួច ព្រះសង្ឃក៏ចាប់យកចង្ហាន់ ដែលរៀបបរិបូរលើតុ យកទៅឆាន់ដោយព្រះអង្គឯងនៅតុដោយឡែកមួយ រួចហើយទាំងអស់គ្នាក៏ចូលទៅចាប់យកម្ហូប ដែលសេសសល់ពីព្រះសង្ឃ គេហៅថា-ម្ហូបបុណ្យហូបក្រោមម្លប់ឈើយ៉ាងសោមនស្សក្រៃលែង ។

ក្នុងដីវត្តទំហំ ២,៥០អេគឺ ឋិតនៅទីក្រុងអ៊ែរ Ayer-ជាជនបទនៃរដ្ឋម៉ាសាឈូសិតទីនោះនឹងមានកំណើតវត្តខ្មែរមួយ ដែលមានដើមឈើធំព័ទ្ធជុំជិត ហាក់ដូចជា នៅស្ងាត់តែម្នាក់ឯងដូច្នោះដែរ, ព្រះអង្គ ប៊ុនតិញ មានសង្ឃដីការថា ទីដីនោះនឹងត្រូវកាត់ឈ្មោះជាសម្បត្តិវត្ត-ភ្នំសេរី នៅថ្ងៃទី១៩


រូបភាពអាគារដែលនឹងក្លាយទៅជាវត្ត

សីហាខាងមុខ ដែលជាថ្ងៃកំណើតរបស់ព្រះអង្គ។

ការដ្ឋានបានបន្តបោសសំអាតបរិវេណវត្តយ៉ាងសកម្មភាពនឹងរីករាយ នារសៀលថ្ងៃអាទិត្យ រហូតដល់ពេលល្ងាច ទើបពុទ្ធបរិស័ទបែកផ្លូវគ្នា ធ្វើដំណើរត្រឡប់ទៅផ្ទះ តែរៀងៗខ្លួន នាំយកនូវភាពរីករាយនឹងទឹកចិត្តបរិច្ចាគទៅជាមួយផងដែរ។



# មណ្ឌលពិនិត្យសុខភាពឡូវែល

## Lowell Primary Care Center

លោកវេជ្ជបណ្ឌិត មុី សុខារិទ្ធ, M.D.
**Sokharith Mey, M.D.**

លោក ចាន់ ទូច , C.N.P.
**Chhan Touch, C.N.P.**





ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី

**Now Accepting New Patients**

ជំងឺទូទៅ
***Family Medicine***

&

សុខភាពផ្លូវចិត្ត
***Behavioral Health***

អាស័យដ្ឋាន

**1075 Westford Street, Unit 204 • Lowell, MA 01851 • (978) 455-7992**

ទទួលយកម៉ាសហែល, មេឌីឃែ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

We Accept MassHealth, Medicare and Other Health Insurances
Our Staff Speaks Khmer • Plenty of Free Parking

"នយោបាយកម្ពុជា"

# ហ៊ុន ម៉ាណែត ជានាយករដ្ឋមន្ត្រីកម្ពុជា

ដោយ ពិន សំខុន

លោក ហ៊ុន សែន បានបញ្ចេញមតិកាលពីសប្តាហ៍មុនថា ចង់ដម្លើងកូនប្រុសច្បងរបស់លោកគឺលោក ហ៊ុន ម៉ាណែត អាយុ៤២ឆ្នាំ ឱ្យទៅជានាយករដ្ឋមន្ត្រីតែមិនបាននិយាយថាសម្រាប់អាណត្តិក្រោយនេះទេ។ យើងនៅតែយល់ថា ពេលវេលា នោះនឹងមកដល់ជាមិនខាននោះទេ! ពីព្រោះលោក ហ៊ុន សែន បានរៀបជើងព្រួលយ៉ាងចំហរជាច្រើនឆ្នាំរួចមកហើយ ដោយដម្លើងសក្តិនឹងដំណែងកំពូលជាបន្តបន្ទាប់នឹងដោយបញ្ជូនកូនមន្ត្រីជាន់ខ្ពស់នៃគណបក្សប្រជាជនខ្លះ ឱ្យឡើងទៅកាន់ដំណែងបន្តពីឪពុក គេជារដ្ឋមន្ត្រីច្រើនគ្នាណាស់ហើយនៅសល់តែកូនខ្លួនឯងតែប៉ុណ្ណោះ ដែលមិនទាន់តែងតាំងឱ្យដល់ដំណែងជាអ្នកស្នងដំណែងជាលោកនាយករដ្ឋមន្ត្រី។

ក្នុងពេលនេះលោក ហ៊ុន សែន គ្រាន់តែបង្ហោះ"បាល់ប៉ោងសម្រាប់ស្ទង់ខ្យល់តែប៉ុណ្ណោះ... យ៉ាងណាក៏ដោយទ្រង់ទ្រាយនៃការតម្លើងបុណ្យសក្តិកូនខ្លួនឯងដោយឪពុកបង្កើតជាមន្ត្រីរបស់ជាតិ គឺជាការ"ខុសសីលធមិនឹងខុសច្បាប់"នៃប្រទេសប្រជាធិបតេយ្យមិនអាចការពារបានឡើយ។ តែបើមានការប្រកួតប្រជែង ដោយតម្លាភាពនឹងយុត្តិធមិមហាជនអាចនឹងស្វាគមន៍បានដែរ ។

**តើ ហ៊ុន ម៉ាណែត អាចឡើងជានាយករដ្ឋមន្ត្រីបានដែរឬ ទេ?**

ម៉េចថាមិនបាន? បើគេដាក់មន្ត្រីជាន់ខ្ពស់ឯទៀតៗ ដែលជាកូនបង្កើតរបស់រដ្ឋមន្ត្រីមុនៗរួចបាត់ទៅហើយ បើទោះជាមិន ស្របតាមក្បួនខ្នាតនៃការជ្រើសរើសបុគ្គលិករដ្ឋក្នុងប្រទេសប្រជាធិបតេយ្យក៏ដោយ, ដូច្នេះហើយបើតាមចរន្តបក្សប្រជាជនលោក ហ៊ុន សែន បានរៀបប្រឡាយបង្ហូរទឹកហូរប្រសព្វមុខឱ្យ ហ៊ុន ម៉ាណែត ជានាយករដ្ឋមន្ត្រីរួចជាស្រេចស្ទើរតែថា "ឡើងពេលណាក៏បានដែរ" គ្រាន់តែធ្វើឱ្យសមដោយធ្វើទៅតាម "ល្បិច" ស្របច្បាប់នៃ"កញ្ច្រោងចាស់"សម្រាប់ជោគជ័យគ្រួសារតែប៉ុណ្ណោះ ហើយនឹងមិនត្រូវទុកបញ្ហាច្រើនពេកឱ្យអនាគតនាយករដ្ឋមន្ត្រី ថ្មីដ៏ក្មេងខ្ចីតែប៉ុណ្ណោះ ។

លក្ខណះសម្បត្តិ ហ៊ុន ម៉ាណែត ជាយុវជនមានកម្លាំងនឹងប្រាជ្ញារហ័សរហួនជាងចាស់ៗធ្លាប់មានដំណែងជាមេទ័ពអាចនឹងទទួលការគាំទ្រច្រើនពីសំណាក់គណបក្សប្រជាជន ដែលជាទូទៅជាមនុស្ស"គរនឹងថ្លង់" ប៉ុន្តែមនុស្សទូទៅវិញគេនឹងមិនអបអរសាទរនឹងវិធីដម្លើងបុណ្យសក្តិក្នុងដំណែងរដ្ឋដូចនេះទេ។ ម្យ៉ាងវិញទៀត បុគ្គលដែលហ៊ានមកទទួលដំណែងតាមវិធីខាងលើនេះ គេនឹងសន្មតថា"ជាយុវជនដែលគ្មានសមត្ថភាពនឹងមិនសុច្ចរិត សម្រាប់ប្រជាជាតិខ្មែរ"នោះទេ ពីព្រោះវាជាការមើលងាយដល់ប្រជាពលរដ្ឋខ្មែរដែលមិនបានជ្រើសរើសមន្ត្រីរបស់ខ្លួន ។

ហ៊ុន ម៉ាណែត ធ្លាប់មានការអប់រំ នៅបច្ចឹមប្រទេសដែរ ដូច្នេះក៏អាចនឹងមានជំនឿលើលទ្ធិប្រជាធិបតេយ្យ, មានជំនឿលើច្បាប់ដែលគ្រប់គ្រងពលរដ្ឋស្មើមុខគ្នាចំពោះមុខច្បាប់។ អាចទប់ទល់ដោយខន្តី ចំពោះស្មារតី"សេរីភាពក្នុងការបញ្ចេញមតិ"របស់ពលរដ្ឋខ្មែរបាន ។ ក្នុងតួនាទីដ៏ច្រើននឹងដ៏ធំហួសមាឌលោកគួរណាស់តែមានបទពិសោធន៍អាចបែងចែក"ល្អនឹងអាក្រក់"ប្រយោជន៍"ជាតិនឹងផ្ទាល់ខ្លួន"បាន ក៏ប៉ុន្តែគុណវិបត្តិក៏យុវជននេះ មានច្រើនណាស់ដែរ ពីព្រោះតែការអនុវត្តន៍ចំណេះ ដែលបានមកពីសាលារៀននៃបច្ចឹមប្រទេសបែរជាយកមកប្រើនៅក្នុងថ្នាលបណ្តុះនយោបាយ"ផ្តាច់ការនិយម", ធ្លាប់តែគ្រប់គ្រងប្រទេសតាមបែប"បក្ខពួកនិយម"។

យុវជននេះ ធ្លាប់តែរស់នៅតែក្នុងរង្វង់នៃអំណាចនៃកាំភ្លើងនឹងអំណាចនៃលុយ,មិនដែលចេញមុខការពារនូវអ្វីដែលយុវជននោះយល់ថា "ត្រូវនឹងប្រកបដោយសិលធមិ"នៅឡើយទេ ជាពិសេសទៅទៀតនោះ សាធារណៈជនរាប់ទាំងសមាជិកគណបក្សប្រជាជនខ្លួនឯងផង មិនបានដឹងថា តើយុវជនដ៏ក្មេងខ្ចី មុខស្រស់នោះមានអ្វីដែលថ្មី ហើយប្រសើរជាងការដឹកនាំរបស់ឪពុកខ្លួននោះនៅឡើយទេ?

**តើហ៊ុនសែនសំអាងអ្វីដែលហ៊ានតែងតាំង ហ៊ុន ម៉ាណែត?**

បើតែងតាំងបាន! ហ៊ុន ម៉ាណែត នឹងក្លាយទៅជានាយករដ្ឋមន្ត្រីដ៏ក្មេងបំផុត នៅក្នុងរបបប្រជាធិបតេយ្យ, តែក៏មានឪពុកជានាយករដ្ឋមន្ត្រីរតែក្មេងជាងទៅទៀត កាលពីជំនាន់"កម្ពុជាប្រជាមានិត"ដែរ នាជំនាន់វៀតណាមបន្ទុប។ តើ ហ៊ុន ម៉ាណែត ចង់បានតួនាទី ដែលឪពុកខ្លួនបន្ទុបដែរឬទេ? នៅបច្ចឹមប្រទេស គេមិនបានបង្រៀនមេរៀនរបៀបនេះទេ! ដូច្នេះ តើ ហ៊ុន សែន នឹងធ្វើរបៀបណាទៅវិញ?

របៀបដែលកំពុងតែអនុវត្តន៍នោះគឺ ១-កុំឱ្យមានបក្សប្រឆាំង ដែលមិនស្តាប់បង្គាប់, ២-កុំឱ្យសម រង្ស៊ី ចូលស្រុកខ្មែរវិញបាន, ៣-កុំដោះលែង កឹម សុខា ឱ្យមានសេរីភាព, ៤-រក្សា រ៉ុងឈុនដែល កំពុងមានប្រជាប្រិយភាពឱ្យនៅក្នុងគុក, ៥- រក្សាសភាឯកបក្ស ឱ្យគង់វង្ស... ធ្វើរបៀបនេះបាន? ហ៊ុន ម៉ាណែត នឹងបានឡើងជានាយករដ្ឋមន្ត្រីជាប្រាកដ។

**ហ៊ុន ម៉ាណែត ជានាយករដ្ឋមន្ត្រី តើត្រូវឆ្លងវិញ្ញាសារដ៏ លំបាកអ្វីខ្លះ?**

**១-សហគមន៍អន្តរជាតិៈ** លោក ហ៊ុន សែន កំពុងតែងាក ទៅរកការគាំទ្រពីចិនកុម្មុយនិស្តឱ្យជួយឧត្តមសេនីយកូនប្រុស ច្បងឱ្យមានដំណោះស្រាយសេដ្ឋកិច្ចនឹងនយោបាយ, ចិនអាចនឹងមកជួយ ក៏ប៉ុន្តែសហរដ្ឋអាមេរិក សហភាពអឺរ៉ុបនឹងប្រទេសមហាអំណាច សេដ្ឋកិច្ចឯទៀត តើគេនឹងដោះលែងដង្កាប រំលោភ សិទ្ធមនុស្សនិទណ្ឌភាព នឹងអំណាចផ្តាច់ការ នៅកម្ពុជាដែរឬទេ? ប្រទេសដែលរងដង្កាបនោះ គឺច្រើនរងទុក្ខវេទនា"រស់ដូចមនុស្សស្លាប់"អ៊ីចឹង...។

២-នៅមានគណបក្សប្រឆាំង គឺអតីតគណបក្សសង្គ្រោះជាតិ ដែលធ្លាប់តែមានតួនាទីជាភ្នែកជាច្រមុះប្រជាជាតិពុំបាន នៅជាប្រយោជន៍ដល់ប្រទេសប៉ុន្មានទេ ពេលនេះ ពីព្រោះតែបានត្រូវរំលាយតាមគម្រោងរួចរាល់ហើយ, លើសពីនេះទៀតនោះ អតីតមេបក្សប្រឆាំងដ៏ល្បីល្បាញម្នាក់នោះក៏ធ្លាប់តែប្រើការឃោសនាភូតកុហករហូតដល់គ្មាននរណាជឿបានទៅហើយ... ដូច្នេះបច្ចុប្បន្ននេះ គួរតែជាដំណឹងដ៏រីករាយ ចំពោះ ហ៊ុន ម៉ាណែត ហើយ!, តែបើមើលទៅយុវជនខ្មែរនឹងប្រជាពលរដ្ឋក្រីក្រ គេហាក់ដូចជាមិនខ្លាចនឹងបញ្ចេញមតិប្រឆាំងរដ្ឋាភិបាល ហើយក៏មិនខ្លាចជាប់គុក ដូចការគិតរបស់ ហ៊ុន សែន នោះទៅទៀត... គេនៅតែចង់ប្តូររបបតែដដែល តើគេចង់បាន ហ៊ុន ម៉ាណែត ដែល បណ្តុបដោយ ហ៊ុន សែន ដែរឬទេ ?

នៅមានក្រុមតស៊ូនយោបាយដៃទទេ ជាអតីតគណបក្សសង្គ្រោះជាតិទៅសុំសិទ្ធធ្វើនយោបាយពួកនោះក៏នៅតែមានបេះដូងជាសង្គ្រោះជាតិគ្មានប្តូរ ទោះជាមានឈ្មោះផ្សេងក៏ដោយ ពួកនោះទៅរួមគ្នាជាមួយពលរដ្ឋដែលលែងខ្លាចស្លាប់ ក៏អាចធ្វើឱ្យ ហ៊ុន ម៉ាណែត រង្គោះរង្គើបានដែរ។ សូមមើលតែគំរូនៅប្រទេសភូមាអំណាចផ្តាច់ការរបស់កងទ័ព ក៏មិនអាចទប់ សាន់ ស៊ូជី ដៃ ទទេ មិនឱ្យឡើងជានាយករដ្ឋមន្ត្រីជំនួសកងទ័ពប្រដាប់អាវុធបាននោះទេ គឺលោកស្រី ស៊ូជី ជ័យលាភីណូបែល បានឡើងជានាយករដ្ឋមន្ត្រី ទោះជាក្រោមច្បាប់របស់ក្រុមយោធានិយមនឹងការគម្រាមកំហែងដល់ជីវិតក៏ដោយ។


លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន


ឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត


លោកប្រធានាធិបតីចិននៃប្រទេស ស៊ី ជីងពីង បានទទួលលោក ហ៊ុន សែន និង ហ៊ុន ម៉ាណែត កាលពីដើមពីដើមឆ្នាំ២០២០ នៅប៉េជីង ទំនងជាមានការគាំទ្រដល់បេក្ខភាព នាយករដ្ឋមន្ត្រីរបស់ ហ៊ុន ម៉ាណែត

# ទីបំផុតតុលាការសម្រេចចេញដីកាឃុំខ្លួនលោក រ៉ុង ឈុន ជាបណ្ដោះអាសន្ន ពីបទ “ញុះញង់បង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម”

ភ្នំពេញ : នៅទីបំផុតសាលាដំបូងរាជធានីភ្នំពេញ សម្រេចចេញដីកាឃុំខ្លួនលោក រ៉ុង ឈុន ជាបណ្ដោះអាសន្នពីបទ "ញុះញង់បង្កឱ្យមានភាពវិកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម" តាមមាត្រា៤៩៥ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

លោក គុជ គីមឡុង ព្រះរាជអាជ្ញារង និងជាអ្នកនាំពាក្យនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានបញ្ជាក់ប្រាប់អ្នកយកព័ត៌មានឱ្យដឹងថា ចៅក្រមស៊ើបសួរ វ៉ាន់ សែនវិសុទ្ធ ក្រោយពីបានសាកសួរតាមនីតិវិធីរួចហើយ បានសម្រេចឃុំខ្លួនលោក រ៉ុង ឈុន ជាបណ្ដោះអាសន្នតាមនីតិវិធី។

លោក រ៉ុង ឈុន ត្រូវបានសមត្ថកិច្ចនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បញ្ជូនទៅកាន់សាលាដំបូងរាជធានីភ្នំពេញនៅព្រឹកថ្ងៃទី០១ ខែសីហា ឆ្នាំ២០២០នេះ បន្ទាប់ពីសមត្ថកិច្ចចាប់ខ្លួននៅយប់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ ពាក់ព័ន្ធនឹងបទល្មើសជាក់ស្ដែងដោយញុះញង់ឱ្យមានភាពវឹកវរដល់សន្តិសុខសង្គមលើបញ្ហាព្រំដែនកម្ពុជា។

មុនពេលមានការឃាត់ខ្លួននេះ លោក រ៉ុង ឈុន បានចុះទៅកាន់ព្រំដែនកម្ពុជា-វៀតណាម ខេត្តត្បូងឃ្មុំ ហើយបានចេញសេចក្ដីថ្លែងការណ៍ញុះញង់ថា ការបោះបង្គោលព្រំដែនថ្មីរវាងកម្ពុជា-វៀតណាមបានចូលមកដីកម្ពុជាប្រហែល៥០០ម៉ែត្រ។

ភ្លាមៗបន្ទាប់ពីមានការចោទប្រកាន់នេះ គណៈកម្មាធិការចម្រុះកិច្ចការព្រំដែនកម្ពុជា បានប្រកាសទាត់ចោលនូវសេចក្ដីថ្លែងការណ៍របស់លោក រ៉ុង ឈុន ដោយចាត់ទុកថា ជាការផ្សាយព័ត៌មានមិនពិត និងបំផ្លើស។

គណៈកម្មាធិការចម្រុះកិច្ចការព្រំដែនចាត់ទុកថាការផ្សាយរបស់លោក រ៉ុង ឈុន មានចេតនា ទុច្ចរិត ក្នុងគោលបំណងបំភាន់សាធារណៈមតិជាតិ និងអន្តរជាតិ ដោយធ្វើការចោទប្រកាន់ដោយគ្មានមូលដ្ឋានមកលើការងារព្រំដែនរបស់រាជរដ្ឋាភិបាល។ FreshNews

### កំណត់ចំណាំពីលោក រ៉ុង ឈុន

បាតុកម្មការពារលោក រ៉ុង ឈុន ថា "លោកមិនបានធ្វើអ្វីខុសនឹងច្បាប់ទេ"នោះ បានផ្ទុះនៅច្រើនកន្លែង ជាពិសេសនៅមុខតុលាការក្រុងភ្នំពេញ ដែលកងសន្តិសុខក្រាស់ឃ្មឹក ខឹតខំទប់ស្កាត់ក្រុមបាតុករ ដែលខឹងសម្បារ គ្មានខ្លាចគុក គ្មានខ្លាចស្លាប់ ទាំងក្មេងទាំងចាស់ មានវត្តមាន តាំងពីថ្ងៃដែលចាប់ខ្លួនលោក រ៉ុងឈុន នោះមក។


លោក រ៉ុង ឈុន

ប្រជាប្រិយភាពលោកបានមកពីលោកជាប្រធានសហជីពគ្រូបង្រៀនតាំងពី១៩៩៤ ធ្វើសកម្មភាពដឹកនាំបាតុកម្មមិនដែលរួញរាជ្រោមជ្រែងដោយសមាជិកសភា សម រង្ស៊ី ហើយរួមដៃគ្នាជាមួយសហជីពកម្មកររបស់លោក ជា វិជ្ជា នាពេលនោះ បានទាមទារសិទ្ធិ និងគុណភាពការងារ ប្រកបដោយការព្យាយាម ធ្វើឱ្យកម្មករនឹងគ្រូបង្រៀនមានជីវភាពប្រសើរឡើងគ្រប់ពេល។ ភាពរឹងមាំនៃទស្សនៈនយោបាយសុច្ចរឹត នឹងកាពារជនក្រីក្រនឹងទន់ខ្សោយ បានរក្សាប្រជាប្រិយភាពលោកឱ្យនៅខ្ពស់ត្រដែតដដែល រហូតដល់ពេលនេះ។

ការចាប់ខ្លួនលោក រ៉ុង ឈុន ពេលនេះ បានធ្វើឱ្យប្រជាពលរដ្ឋអ្នកនយោបាយដែលយុត្តិធមិ សហគមន៏ខ្មែរនៅបរទេសនឹងសហគមន៏អន្តរជាតិ ឈរនៅខាងលោក រ៉ុង ឈុន ទាំងអស់គ្នា ប៉ុន្តែតុលាការខ្មែរ នឹងសមត្ថកិច្ចខ្មែរ បានចោទប្រកាន់ដោយសារតែប្រជាប្រិយភាពដែលអាចប្រឈមនឹងអំណាចលោក ហ៊ុន សែន។







50 years
1970 – 2020
MIDDLESEX
Community College
Things change. MCC's tuition won't.
Discover YOUR Path
CLASSES START Sept. 9
Register Today!
MCC will not increase tuition costs for the 2020-2021 academic year
Call 1-800-818-3434 or visit www.middlesex.mass.edu/fall2020


មណ្ឌលពិនិត្យសុខភាពលីន
Lynn Primary Care Center
លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, M.D.
Sokharith Mey, M.D.
ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី
Now Accepting New Patients
អាស័យដ្ឋាន
280 Union Street, Unit 402 • Lynn, MA 01901 • (781) 780-7755
ទទួលយកម៉ាសហែល, មេឌីឃែ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ
LYNN PRIMARY CARE CENTER
LPCC
មណ្ឌលពិនិត្យសុខភាពលីន
ជំងឺទូទៅ
Family Medicine
សុខភាពផ្លូវចិត្ត
Behavioral Health
We Accept MassHealth, Medicare
and Other Health Insurances
Our Staff Speaks Khmer

# ការរស់នៅក្នុងរដូវក្តៅនៅ ញូ អ៊ីងលិន ពេលកើតមានជំងឺកូវីត១៩

ដោយ សុបិន ពិន

បន្ទាប់ពីមានការរិតត្បិតក្នុងការប្រាស្រ័យទាក់ទងអស់រយៈពេលជិតបួនខែកន្លងទៅចាប់តាំងពីមានការផ្ទុះឡើងនូវមេរោគកូរ៉ូណានៅខែមិនាមក ប្រជាជនកំពុងតែព្យាយាមស្វែងរកនូវការរស់នៅធម្មតាថ្មីរបស់ពួកគេ ដែលបានយល់ដឹងពីការបាត់បង់អាយុជីវិតរាប់ពាន់នាក់ជារៀងរាល់ថ្ងៃនៅទូទាំងសហរដ្ឋអាមេរិក ។ នៅញ៉ូ អ៊ីងលិន រដ្ឋម៉ាសាជូសេតដែលខ្ញុំរស់នៅមានមនុស្សលើសពី១០០,០០០នាក់ហើយ ដែលបានឆ្លងនូវជំងឺកូវីត១៩ ហើយជិត១០,០០០នាក់បានបាត់បង់ជីវិត ។ ខ្ញុំផ្ទាល់បានទទួលរងការប៉ះពាល់យ៉ាងខ្លាំងក្នុងកំឡុងពេលការកើតមានជំងឺនេះ ដោយបានបាត់បង់ម្តាយរបស់ខ្ញុំដោយសារជំងឺមហារីក ហើយខ្ញុំក៏មិនអាចធ្វើដំណើរទៅជួបគាត់លើកចុងក្រោយបានដោយសារតែការរិតបន្តឹងការធ្វើដំណើរ ។ ការបិទហាងលក់ដូរធ្វើឱ្យការចែកចាយនូវការបោះពុម្ពផ្សាយមានការធ្លាក់ចុះក្នុងរយៈពេលបីខែចុងក្រោយនេះ ប៉ុន្តែយើងអាចគ្រប់គ្រងការបោះពុម្ពចំនួន ពីរលេខ





Windmill Beach, South Yarmouth, MA

ដោយមានការកាត់បន្ថយបរិមាណក្នុងនោះបោះពុម្ពម្តងនៅខែក្នុងឧសភា និងមួយលេខទៀតនៅខែមិថុនា ។ សម្រាប់ខែកក្កដា ដោយសារតែនៅញ៉ូអ៊ីងលិន បានបើកសេដ្ឋកិច្ចឡើងវិញសម្រាប់ដំណាក់កាលទី២នោះ យើងបានចាប់ផ្តើមបោះពុម្ពផ្សាយធម្មតាឡើងវិញចំនួនពីរលេខក្នុងមួយខែ ។

ក្នុងរយៈពេលពីរសប្តាហ៍ចុងក្រោយនេះ យើងបានចំណាយពេលចេញធ្វើដំណើរចេញក្រៅជាលើកដំបូងបន្ទាប់ពីការរស់នៅដោយឡែកអស់រយៈពេល៣ខែ ។ យើងបានធ្វើដំណើរទៅកាន់តំបន់ឆ្នេរខាងលើ និងខាងក្រោមរវាងញ៉ូផតប៊ិច (Newport Beach) រដ្ឋរ៉ូត អាយលិន ទៅកាន់ក្រុង ខេប ខូឌ (Cape Cod) រដ្ឋម៉ាសាជូសេត, ទៅកាន់ក្រុង ញ៉ូ ខាសល ( New Castle) រដ្ឋញ៉ូ ហេមឈ័រ និងទៅកាន់ទីក្រុង អូហ្គានខ្វិត (Ogunquit) និង ផូលិន (Portland) នៅរដ្ឋម៉េន (Maine) ។ ខ្ញុំនឹងធ្វើការចែករំលែកនូវអ្វីដែលខ្ញុំបានដឹងរហូតកន្លងមកដើម្បីឱ្យលោកអ្នកអាចធ្វើការប្រុងប្រយ័ត្នក្នុងការនាំគ្រួសាររបស់លោកអ្នកចំពោះការធ្វើការចេញក្រៅក្នុងរដូវក្តៅនេះ ។ របៀបធម្មតាថ្មីដែលយើងត្រូវតែធ្វើការដើម្បីសម្របខ្លួនទៅនឹងការរស់នៅប្រចាំថ្ងៃរបស់យើង គឺថាយើងទាំងអស់គ្នា ត្រូវតែត្រឡេកមើលអ្វីៗទាំងអស់នៅជុំវិញយើងតាមវិធីថ្មី ។

ដោយសារតែរដ្ឋជាច្រើន ចាប់ផ្តើមបើកដំណើរផ្នែកមួយចំនួននៃសេដ្ឋកិច្ច ដូចជាភោជនីយដ្ឋាន, ឆ្នេរសមុទ្រ ជាដើមនោះ យើងបានឃើញថាខ្លួនយើងកាន់តែមានអារម្មណ៍កក់ក្តៅក្នុងការធ្វើដំណើរទៅកាន់គោលដៅដែលមានមនុស្សមិនច្រើនចូលចិត្តធ្វើដំណើរទៅនោះ ។ ការធ្វើដំណើរដោយរថយន្ត គឺជួយយើងក្នុងការរកទីតាំងដែលយើងអនុញ្ញាតឱ្យយើងធ្វើការបោះតង់ក្នុងមួយថ្ងៃ ដូចជានៅថ្ងៃនេះ យើងបានប្រទះកោះមួយដែលជាធម្មតាយើងនឹងមិនស្វែងរកនោះទេ គឺកោះ Cape Elizabeth ។ នៅទីនេះ យើងបានទៅលេងឧទ្យានជាតិ វីល្យែម ផាក (Port William State Park ) ដែលជាកន្លែងមាន



សុបិន្ត ពិន

តុកម្សាន្តជាច្រើនដែលមានទេសភាពសមុទ្រ, ឆ្នេរ និងប៉មពន្លឺដ៏ស្រស់ស្អាតពីរ ដែលជាផ្នែកមួយនៃឆ្នេរសមុទ្ររបស់ទីក្រុងផូលិន (Portland) នៅរដ្ឋម៉េន (Maine) ។

ចំពោះការស្នាក់នៅសណ្ឋាគារយើងបានយកប្រភេទ ( Spray ) បាញ់ដែលមានកំរិតអាកុល៧០% និងបាញ់វាពេញបន្ទប់បន្ទាប់ពីយើងចូលទៅក្នុងបន្ទប់ រួមមានតេលេបញ្ជាទូរទស្សន៍, កូនសោរ, និងប្រដាប់ទាញទ្វារបិទបើក ។ យើងពាក់ម៉ាស់នៅពេលដែលយើងនៅជិតនឹងអ្នកផ្សេងទៀតរហូតដល់យើងទៅដល់គោលដៅរបស់យើង ហើយក៏មិនបាននៅជិតនឹងមនុស្សផ្សេតទៀតដែរ ។ យើងមានអារម្មណ៍ថា មានសុវត្ថិភាព ។ យើងរក្សាទុកនូវប្រភេទ ( Spray ) បាញ់នេះនៅក្នុងកាបូបលុយរបស់ខ្ញុំ ហើយបាញ់ដៃរបស់យើងមុន និងបន្ទាប់ពីយើងបរិភោគអាហារ ។ យើងបានជ្រើសយកការកម្មង់អាហារហូបខាងក្រៅ នៅពេលដែលអាហារដ្ឋានពេញទៅដោយមនុស្ស បើទោះបីជាតុអាហារត្រូវបានរៀបចំដោយមានគំលាតពីគ្នារវាង៦ហ្វីតក៏ដោយ ។ យើងចូលចិត្តអង្គុយខាងក្រៅព្រោះ វាមានមនុស្សនៅគំលាតពីគ្នាជាង១០ហ្វីត ។ រហូតមកដល់ពេលនេះ យើងមិនមានបញ្ហាពីការរក្សាគំលាតពីគ្នាតែមានការលើកលែងមួយចំនួនតូចនៅកណ្តាលក្រុង Portland រដ្ឋម៉េន និងនៅឆ្នេរសមុទ្រ Newport Beach ដែលមានយុវជនជាច្រើនធ្វើការច្របូលផ្តុំគ្នានៅឯភោជនីយដ្ឋាន និងបារនៅក្នុងហ្វូងមនុស្សជាច្រើន ។ ទង្វើនេះអាចជាបញ្ហាអោយយើងឃើញពីករណីកូវីត១៩កំពុងតែរីករាលដាលក្នុងចំណោមមនុស្សពេញវ័យដែលមានអាយុក្រោម៤០ឆ្នាំ ។ យោងតាមមជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺ (CDC) ៩០០ ពាន់ករណីកំពុងតែកើតឡើងនៅក្នុងចំណោមមនុស្សវ័យក្មេងដែលមានអាយុចន្លោះ១៨-៤៤ឆ្នាំ, ៧០០ពាន់ករណីចន្លោះអាយុរវាង ៤៥ ˜ ៦៤ ឆ្នាំ និង ២០០ ពាន់ករណីអាយុចាប់ពី ៦៥ និងអាយុច្រើនជាងនេះដែលបានឆ្លងកូវីត១៩នេះ ។

ខណៈនៅរដ្ឋម៉េន យើងបានឃើញមនុស្សម្នាមានការលំហែកាយ លើកលែងតែអ្នកបំរើការងារផ្នែកសេវាមានការមមាញឹកនឹងការងារ ហើយមានតែមួយចំនួនប៉ុណ្ណោះដែលបានពាក់ម៉ាស ហើយយើងមានអារម្មណ៍ថា វាគួរអោយខ្លាចណាស់ ។ ទោះបីជាយ៉ាងណាក៏ដោយយើងអាចយល់បានថា នៅក្នុងរដ្ឋដែលមានចំនួនប្រជាជន ១.៣ លាននាក់ មានតែចំនួន ២០០ នាក់ បានស្លាប់ដោយកូវីត១៩ ហើយច្រើនជាង ៣,០០០ ករណី ប្រជាជនមិនមានអារម្មណ៍គំរាមគំហែងពីសំណាក់មេរោគកូវីត១៩នោះទេ ។ ដូចគ្នានៅនឹងចំនួនប្រជាជននៅរដ្ឋម៉េន និងនៅក្នុងរដ្ឋ ញូវហេមឈ័រ មានករណីឆ្លងកូវីត១៩ ចំនួន ៥,៦០០ ករណី និង ៣៦៥ នាក់បានស្លាប់ ។ ប្រៀបធៀបទៅ និងរដ្ឋម៉ាសាជូសេតដែលមានប្រជាជនកើតនឹងស្លាប់ខ្ពស់ជាង៩ដង ទៅនិងរដ្ឋ រ៉ូតអាយលេន តទៅទំព័រទី ០៩



Downtown Portland, Maine closed several streets for restaurants to serve outdoors dining.

តមកពីទំព័រទី ០៨

# ការរស់នៅក្នុងរដូវក្តៅនៅ ញូ អ៊ីងលិន

ចំនួនមនុស្សដែលឆ្លងមាន១៦,០០០នាក់ និង ស្លាប់៩០០នាក់។ ចំនួនប្រជាជនសរុបនៃរដ្ឋនេះ គឺ១លាននាក់។

ទោះបីជានិន្នាការនៃចំនួនអ្នកកើតនៅរដ្ឋម៉ាសាជូសេតកំពុងតែថយចុះពី៩,០០០ករណីក្នុងមួយថ្ងៃក្នុងសប្តាហ៍ទី ៣នៃខែមេសាដែលមានត្រឹមតែ២៣៣ករណី ក្នុងមួយថ្ងៃគិតត្រឹមខែកក្កដាយ៉ាងណាក៏ដោយ អ្នកជំនាញបានមានប្រសាសន៍ថា ករណីឆ្លងជាលើកទី២កំពុងកើតឡើង។យើងសង្ឃឹមថារដ្ឋម៉ាសាជូសេតនឹងមិនមានការកើតឡើងនោះទេ ប៉ុន្តែយើងមិនអាចដឹងអោយប្រាកដនោះទេ។

នៅក្នុងសហរដ្ឋអាមេរិច មានករណីឆ្លងច្រើនជាង២៥លាននាក់ ហើយចំនូននាក់ស្លាប់១២៥,០០០នាក់។ ករណីឆ្លងកំពុងតែមានការកើនឡើងនៅក្នុងរដ្ឋដូចជា រដ្ឋហ្វ្លរីដា មានការឆ្លងថ្មី ៩,០០០ ករណី ក្នុងមួយថ្ងៃនៅថ្ងៃទី២៦ ខែមិថុនានៅស្របពេលដែលរដ្ឋនេះបានបើកដំណើរការសេដ្ឋកិច្ចរបស់ខ្លួនឡើងវិញបានប៉ុន្មានជាពីរបីសប្តាហ៍ប៉ុណ្ណោះ ដែលជារលកទី២ កំពុងតែវាយប្រហារ។ នៅក្នុងរដ្ឋតិចសាសមនុស្សម្នាក់ក្នុងចំនោម១០នាក់ គឺបានឆ្លងជំងឺនេះ។ រដ្ឋអារីសូណា និងរដ្ឋកាលីហ្វញ៉ា ក៏កំពុងតែកើនឡើងនៃការឆ្លងផងដែរ។ ប្រសិនបើលោកអ្នកមាន គំរោងទៅកាន់រដ្ឋទាំងនេះ លោកអ្នកអាចត្រូវឱ្យនៅដោយឡែកនៅពេលត្រលប់ទៅកាន់រដ្ឋដូចជា ខន់ណិតធីឃិត, ញូយ៉ក និង ញូរជេ ស៊ី។



ជាចុងក្រោយខ្ញុំសូមធ្វើការណែនាំថា អ្នកអានទាំងអស់គួរស្នាក់នៅញូអ៊ីនឡែនក្នុងរដូវក្តៅនេះ យើងគួរជៀសវាងធ្វើដំណើរតាមជើងយន្តហោះ ប្រសិនបើមិនមានការចាំបាច់នោះទេ។ ខ្យល់ដែលមានក្នុងយន្តហោះ វាធ្វើអោយមេរោគនៅវិលវល់ពាសពេញយន្តហោះ ទោះបីជាកៅអីនៅកណ្តាលយន្តហោះមិនមានអ្នកអង្គុយក៏ដោយ ដោយសារមិនមានគំលាតពីគ្នាគ្រប់គ្រាន់នោះទេ ហើយលោកអ្នកត្រូវតែពាក់ម៉ាសគ្រប់ពេល។

ការរស់នៅតាមរបៀបធម្មតាថ្មីនេះគឺថា យើងគួរតែមើលរបៀបនៃជីវិតគ្រួសារតាមបែបសាមញ្ញដែលធ្លាប់មាននៅពេលដែលមានការកំរិតនៃបារ, ភោជនីយដ្ឋាន, រោងភាពយន, និងកន្លែងហាត់ប្រាណនោះ។ យើងគួរតែចាត់ទុកសកម្មភាពទាំងនេះជាទង្វើដ៏ប្រសើរបំផុតសំរាប់ឥឡូវនេះ ក្នុងពេលដែលកើតមេរោគកូវីត១៩ ហើយត្រូវរក្សាការអនុវត្តន៏គំលាតសង្គម ។ នៅពេលលោកអ្នកមានអារម្មណ៏មិនស្រួល គួរតែនៅផ្ទះ។ នៅពេលលោកអ្នកមានអារម្មណ៏ថាមានរោគសញ្ញាដូចជាផ្តាសាយរួមមានការបាត់បង់ក្លិននោះ លោកអ្នកគួរទៅធ្វើតេស្តកូវីត១៩។ អ្នកជំនាញបាននិយាយថា អាចមានករណីឆ្លងដល់ពលរដ្ឋអាមេរិចច្រើនជាង ២.៥ លាននាក់ នៅពេលឥឡូវនេះ ដោយសារតែលទ្ធភាពនៃការធ្វើតេស្តមានកំរិត។ ដូច្នេះគួរតែធ្វើការប្រុងប្រយ័ត្ន។ ក្នុងរយៈពេល ៨ ខែចុងក្រោយនេះ មានមនុស្ស ២០លាននាក់ ដែលបានឆ្លងមេរោគកូវីត ១៩ ហើយមនុស្សជាងកន្លះលាននាក់បានស្លាប់នៅទូទាំងពិភពលោក។ ខ្ញុំសូមជំរុញឱ្យអ្នកទាំងអស់គ្នាបន្តរក្សាគំលាតសង្គម ហើយសូមមានសុវត្ថិភាព។បញ្ហាមេរោគនេះអាចនឹងមានរយៈពេលដល់ទៅ៦ខែទៀត។នៅសហរដ្ឋរហូតមកទល់ពេលនេះ មានករណីឆ្លងកូវីត១៩ ចំនួន៥លាននាក់ហើយ និងមានករណីស្លាប់ដោយសារកូវីត១៩ ចំនួន១៦.០០០០នាក់ ។




S W H
Senior Whole Health.
A MAGELLAN COMPANY

គម្រោងថែទាំសុខភាពសម្រាប់មនុស្សចាស់ជាមួយនឹងកម្មវិធី MassHealth ។

យើងនិយាយជាភាសារបស់អ្នក

យើងនិយាយបានជាង 40 ភាសា ហើយយើងនឹងជួយអ្នកឲ្យទទួលបានការថែទាំពីគ្រូពេទ្យដែលយល់អំពីអ្នក!

ស្វែងយល់បន្ថែម។ ហៅទូរស័ព្ទមក 1-888-566-3526 (TTY 711)។
www.seniorwholehealth.com

កម្មវិធី Senior Whole Health គោរពតាមច្បាប់ស្តីពីសិទ្ធិពលរដ្ឋសហព័ន្ធដែលចូលជាធរមាន និងមិនធ្វើការរើសអើងដោយសារពូជសាសន៍ ពណ៌សម្បុរ ដើមកំណើតជាតិសាសន៍ អាយុ ពិការភាព ឬភេទឡើយ។ កម្មវិធី Senior Whole Health (HMO SNP) និង Senior Whole Health NHC (HMO SNP) គឺជាផែនការថែទាំសម្របសម្រួលដែលមានកិច្ចសន្យា Medicare Advantage និងកិច្ចសន្យាជាមួយសហធនរដ្ឋ Massachusetts /កម្មវិធី EOHHS MassHealth។ ការចុះឈ្មោះអាស្រ័យលើការបន្តកិច្ចសន្យារាល់ឆ្នាំ។
H2224-2020-84533 _M KHM Approved 2/11/2020

# សមាជិក"អេសេឡិក"ម្នាក់មានទុក្ខជាទម្ងន់

សមាគម"អេសេឡិក" ASALEC"សូមចូលរួមរំលែកមរណទុក្ខយ៉ាងក្រៀមក្រំជាមួយនឹងគ្រួសារលោក ចក្រី ឯម ដែលជាសមាជិកគណកម្មការនាយកសមាគមដោយកូនស្រីលោកអាយុ ២៥ ឆ្នាំ ឈ្មោះ ថេរីកា ជូឌិត ផេង Tierica Judith Pang បានទទួលមរណភាពដោយវិបត្តិផ្លូវចិត្ត កាលពីថ្ងៃទី៧ សីហា ២០២០នេះ។

សមាជិកនៃសមាគមយើងទាំងអស់ សូមសម្តែងសមាណចិត្តទោមនស្សសោកស្តាយជាអនេកកប្បការជាមួយនឹងក្រុមគ្រួសារសព ចំពោះការបាត់បង់ជីវិតយុវតីដែលដូចជាកូនក្មួយដ៏ស្រស់ស្អាតក្នុងគ្រួសារប្រកបដោយធម៌ហើយ ដែលធ្លាប់តែជួយឈឺឆ្អាលដល់ទុក្ខព្រួយអ្នកដទៃ។

សូមឱ្យវិញ្ញាណក្ខន្ធកញ្ញា ថេរីការ ទីស្រឡាញ់របស់ញាតិសណ្តានទទួលនូវការបីបាច់ថ្នាក់ថ្នមថែរក្សា នាសុគតិភព កុំបីឃ្លាងឃ្លាតឡើយ។ នាងថេរីកាបានរៀនចប់មហាវិទ្យាល័យរស់នៅទីក្រុង "បូស្តុន"ជាមួយសង្សានាង រហូតដល់ថ្ងៃដែលនាងទទួលដំណឹងពីវេជ្ជបណ្ឌិតថា"នាងមានជម្ងឺមហារីក" ដែលជាហេតុនាំឱ្យនាងទ្រាំមិនបាន ក៏ដាច់ចិត្តបញ្ចប់ជីវិតមុនពេលដែលជម្ងឺ អាចនឹងយកជីវិតនាងនាពេលណាមួយខាងមុខ។

**កំណត់ចំណាំៈ** ជម្ងឺផ្លូវចិត្តដែលគេតែងយល់ថា មិនអាចមានគ្រោះថ្នាក់ដល់ជីវិតទេនោះ គឺជាការយល់ច្រឡំដ៏ធំមួយ។ លោកអ្នកជាអនាព្យាបាល ឬជាមិត្តជិតស្និតត្រូវតែដឹងថា"ជីវិតអ្នកជម្ងឺអាចនឹងមានការគ្រោះថ្នាក់គ្រប់ពេល រួមទាំងអ្នកដែលរស់នៅជុំវិញអ្នកជម្ងឺផង"។ ដូច្នេះសូមឱ្យមានការប្រុងប្រយ័ត្នដូចតទៅៈ


រូបថតចុងក្រោយរបស់កញ្ញា ថេរីកា

១-នៅពេលដែលអ្នកជម្ងឺទទួល"ថ្នាំរម្ងាប់កំហឹងក្នុងចិត្ត"ពីវេជ្ជបណ្ឌិត សូមកុំទុកអ្នកជម្ងឺនៅតែឯកឯង រយៈពេលយូរឱ្យសោះ សូមនិយាយណែនាំលើកទឹកចិត្តរីករាយ រំសាយចិត្ត កុំបង្កើតជាបញ្ហាអ្វីឱ្យគ្នា...។

២-បើទុកថ្នាំឱ្យកាន់ខ្លួនឯង សម្រាប់លេបប្រចាំថ្ងៃ ក៏កុំទុកឱ្យលើសពី២ថ្ងៃ ដែលអ្នកជម្ងឺនៅពេលមានវិបត្តិអាចនឹងប្រើលើសចំនួនដោយមិនដឹងខ្លួន...។


ថេរីកា តែងតែរីករាយជានិច្ចជាមួយនឹងប្អូនបង្កើតរបស់គេ

៣-សូមកុំទុកកាំបិត ឬអាវុធការពារខ្លួន នៅទីដែលអ្នកជម្ងឺអាចងាយរកឃើញឱ្យសោះ ពីព្រោះពេលផ្ទុះវិបត្តិ គេអាចប្រើប្រាស់សម្រាប់ធ្វើបាបខ្លួនឯង ឬក៏អ្នកដែលនៅជិតខ្លួន...។

សូមរំលឹកថាសហគមន៍ខ្មែរយើងសម្បូរអ្នកដែលមាន"ជម្ងឺផ្លូវចិត្ត"នោះណាស់ ដោយសារតែប្រវត្តិសង្គ្រាមខ្លោចផ្សារនៃប្រទេសយើង, មនុស្សជាច្រើន មិនបានទទួលស្គាល់ថា"ខ្លួនឯងមានផ្ទុកជម្ងឺផ្លូវចិត្ត"នោះទេ ។ គេកត់សម្គាល់បាននៅពេលអ្នកនោះ ឆាប់អាក់អន់ ស្រពន់ចិត្ត ឆាប់ខឹង ប្រកែកប្រកាន់យ៉ាងឆាប់រហ័ស ហើយចូលចិត្តនឹកទៅដល់វិធីទណ្ឌកម្ម ឬទារុណកម្ម សម្រាប់ដោះស្រាយបញ្ហាអ្វីមួយ ។

សូមប្រញាប់និយាយប្រាប់គ្រូពេទ្យរបស់ លោកអ្នក ឬរបស់អ្នកផ្ទះអំពីអាការៈឆាប់ខឹងការវាយប្រដៅ ឬធ្វើបាបកូនចៅខឹងសម្បាររហូតដល់វាយចានឆ្នាំង ឬវាយសត្វក្នុងផ្ទះ អាការៈ ឆេវឆាវហឹង្សា... វានឹងកាត់បន្ថយភាពគ្រោះថ្នាក់នឹងហឹង្សាបានច្រើនក្នុងសហគមន៍យើង។



## តើសមាគម“អេសេឡិក”មានអ្វីខ្លះ សម្រាប់បំរើសហគមន៍យើងនៅឡូវែល

“អេសេឡិក”ជាសមាគមបំរើសហគមន៍អាស៊ាន អាមេរីកាំង នៅឡូវែល មិនស្វែងរកកំរៃ, ទីស្នាក់ ការនៅ ASALEC 325 Chelmsford St. Lowell, MA 01851 លោកអ្នកដែលត្រូវការជំនួយផ្ទាល់ខ្លួន ឬសម្រាប់គ្រួសារយើងមានសេវាដូចតទៅ:

១-សេវាពិគ្រោះយោបល់គ្រួសារ Family advocate services
២-សេវាសុំប័ណ្ណបើកម្ហូប Food stamp services
៣-សេវាសុំអត្តសញ្ញាណប័ណ្ណនឹងប័ណ្ណស្នាក់អាស្រ័យ ID & Green Card service
៤-សេវាណែនាំទៅរៀនមហាវិទ្យាល័យ College planning services
៥-សេវាធ្វើលិខិតអន្តោប្រវេសន៏ធានាម្តាយឪពុក ឬបងប្អូន Immigration service
៦-សេវាសុំប្រាក់ឥតការងារធ្វើ Unemployment service
៧-សេវារដ្ឋបាលនឹងសង្គម Social Services
៨-សេវាធ្វើតាក់9បង់ពន្ធ Tax service
៩-សិក្សាភាសាខ្មែរលើកុំព្យូទ័រ Cambodian Class
១០-រៀន IXL សម្រាប់បង្រៀនកុមារនឹងយុវជន IXL Class for kids
១១-សិក្សាសម្រាប់ប្រឡងចូលសញ្ជាតិអាមេរិកាំង Citizenship class
១២-រៀនប្រឡងយកប័ណ្ណបើកបរ Learning Permit Class
១៣-សិក្សាភាសាអង់គ្លេស English Class
១៤-សិក្សាមូលដ្ឋានប្រើកុំព្យូទ័រ Computer basic Class
១៥-សិក្សាពីហិរញ្ញវត្ថុគ្រួសារ Financial Education class
១៦-សេវាផ្សព្វផ្សាយសង្គម Social Media

បើលោកអ្នកត្រូវការប្រើសេវាណាមួយ សូមទូរស័ព្ទមក (978)-942 8490 ឬ (978)728 2737

## ក្រុមហ៊ុនអចលនៈទ្រព្យ អឺប៊ឺន រាលអ៊ីស្តេត

## URBAN REAL ESTATE

មជ្ឈមណ្ឌលផ្តល់សេវាជួលលំនៅដ្ឋាន

Residential Leasing Center



ដាញ៉េល តាន ភ្នាក់ងារអចលនៈទ្រព្យ

**Daniel Tan**
Real Estate Agent
Cell: 978-902-6354

508 Westford Street • Lowell, MA 01851
(978) 454-0444

## ក្រុមហ៊ុនធានារ៉ាប់រង ឃេឃេ អ៊ីនសួរិន អេជេនស៊ី

## KK Insurance Agency, Inc.

រថយន្ត • លំនៅដ្ឋាន • អាជីវកម្ម

Car • Home • Business



508 Westford Street
Lowell, MA 01851
978-970-2212
kk@kkinsurancema.com

## ការិយាល័យច្បាប់ រ៉ូសា និង តាំង



Francisco J. Rosa, Esq.
មេធាវី ហ្វ្រាំង ស៊ីស្កូ ជេ.រ៉ូសា



Andrew ´Bunna´ Taing, Esq.
មេធាវី អែន ឌ្រូវប៊ុណ្ណា តាំង

Law Office of
**Rosa & Taing**
ATTORNEY AT LAW

| SERVICES | តំណាងក្តីដូចខាងក្រោម |
| --- | --- |
| • Auto Accidents/ Personal Injury | • គ្រោះថ្នាក់រថយន្ត/ របួសរូបរាងកាយ |
| • Bankruptcy | • ក្ស័យធន |
| • Immigration | • អន្តោប្រវេសន៍ |
| • Consumer Protection | • ការពារអតិថិជន |
| • Real Estate Closings/Disputes | • វិវាទលើផ្នែកអចលនវត្ថុ |
| • Divorces Child Custody | • លែងលះ និងអាណាព្យាបាលកិច្ច |

1550 Middlesex Street Lowell, MA 01851
Phone: **978-458-0934** | at@rosataing.com



## CONWAY
INSURANCE AGENCY

រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវេយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។

យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :

| ការធានារ៉ាប់រងគ្រួសារ | ការធានារ៉ាប់រងជំនួញ |
| --- | --- |
| • រថយន្ត | • អចលនវត្ថុ |
| • ផ្ទះ | • សុវត្ថិភាពជំនួញ (Liability) |
| • ផ្ទះល្វែង | • សុវត្ថិភាពជំនាញ (Professional Liability) |
| • គ្រឿងអលង្ការ | • វៃកឺខម (Worker's Compensation) |
| • វត្ថុសិល្បះ | • បនដស៍ (Bonds) |
| • វត្ថុបុរាណ | • អ្នកមើលថែម្ជាន និងការ៉ាស់ម្ជាន |
| | • ធានារ៉ាប់រងពិការភាព និងជីវិត |
| | • កម្មវិធីពិសេសផ្សេងៗទៀត |

CONWAY INSURANCE AGENCY

77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង

# លោក សួង សុភ័ណ្ឌ ត្រូវបានសមត្ថកិច្ចចាប់ខ្លួន ពាក់ព័ន្ធបទល្មើសជាក់ស្តែងទាក់ទងការបំភ្លៃការពិតលើបញ្ហាព្រំដែន

ភ្នំពេញ ៖ លោក សួង សុភ័ណ្ឌ ប្រធានគណបក្ស ល្មើសជាក់ស្តែងទាក់ទងនឹងការញុះញង់បំភ្លៃការ ពិតលើបញ្ហាព្រំដែន និងការចោទប្រកាន់មួលបង្កាច់






ខ្មែរឈ្មោះ ត្រូវបានសមត្ថកិច្ចចាប់ខ្លួន នៅរសៀលថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០នេះ ពាក់ព័ន្ធបទល្មើសជាក់ស្តែងទាក់ទងនឹងការញុះញង់បំភ្លៃការពិតលើបញ្ហាព្រំដែន ។

លោក គុជ គីមឡុង ព្រះរាជអាជ្ញារង និងជាអ្នកនាំពាក្យនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានបញ្ជាក់ប្រាប់បណ្តាញព័ត៌មាននៅរសៀលថ្ងៃទី១៤ ខែសីហានេះថា "លោក សួង សុភ័ណ្ឌ ពិតជាត្រូវបានចាប់ខ្លួនមែន ក្នុងបទ



ទម្លាក់កំហុស លើគណៈកម្មាធិការចម្រុះកិច្ចការព្រំដែនថា ប្រព្រឹត្តបទល្មើសក្បត់ជាតិ" ។

លោក គុជ គីមឡុង បញ្ជាក់ថា បច្ចុប្បន្នលោក សួង សុភ័ណ្ឌ ត្រូវបានឃាត់ខ្លួននៅស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ដើម្បីអនុវត្តនីតិវិធីបន្តតាមច្បាប់ ហើយអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ នឹងជូនព័ត៌មានលំអិតនាពេលក្រោយទៀត ។

តមកពីទំព័រទី ០១

## កាម្លា ហារីស ត្រូវបាន...

១៤ពិន្ទុទៅហើយ មុនពេល កាម្លា ហារីស មកដល់, គេសង្ឃឹមថាពិន្ទុនោះ នឹងកើនគម្លាតកាន់តែខ្ពស់ជាមួយដៃគូរថ្មីរបស់ ជោ បាយដិន ដោយសារតែជាស្ត្រីដំបូងបង្អស់ជានារីស្បែកខ្មៅដំបូងបង្អស់នឹងជានារីអាស៊ីដំបូងបង្អស់ជាបេក្ខនារីអនុប្រធានាធិបតីសហរដ្ឋ



លោក ឌុណល ត្រម និងលោក ម៉ាយផេន

អាមេរិក ។

ចំណែកលោកប្រធានាធិបតី ត្រាំ ក៏កំពុងតែលុងក្នុងអំណាចទប់បាតុកម្មប្រឆាំងភាពរើងអើងពូជសាស្រ្តមិនទាន់ចប់ផង ឥឡូវនេះ ចុះហត្ថលេខាជាអត្ថនោម័តចាយលុយរាប់"ទ្រីល្យុង"ដោយគ្មានឆន្ទៈរបស់សភា គឺជាការរំលោភរដ្ឋធម្មនុញ្ញជាថ្មីម្តងទៀត ដែលសភាទាំងពីរគ្មាននរណាពេញចិត្តនឹងឱ្យឆ្លងរួចនោះទេ, ចំណែកឯប្រាក់"ស្ទីមីឡឹសទី២"លោកត្រាំមិនបានចុះហត្ថលេខានៅឡើយទេ ។

# រមណីយដ្ឋានធម្មជាតិស្អាតពិតៗ សំងំលាក់ខ្លួននៅខេត្តកំពត



ខេត្តកំពតជាទឹកដីដ៏ពេញនិយមមួយសម្រាប់ភ្ញៀវទេសចរកម្រនឹងរំលងណាស់ឱ្យតែដល់ថ្ងៃឈប់សម្រាកម្តងៗ ។ ខេត្តកំពតគ្របដណ្តប់ដោយសក្តានុពលទេចរណ៍ដ៏សម្បូរបែប មានដងអូរ ដងជ្រោះ ព្រៃភ្នំ ដងព្រែកដ៏ល្បីល្បាញបំផុត ។ នៅសប្តាហ៍នេះប្រសិនបើប្រិយមិត្តមានគម្រោងទៅកម្សាន្តនៅខេត្តមួយនេះ យើងសូមណែនាំរីសតមួយ ព្រមទាំងនៅប្របនឹងមាត់ព្រែកទៀតផង ។

**-ម៉ូលីរីសតកំពត ៖** ជាកន្លែងលំហែរកាយ មួយទើបតែបង្កើតឡើងថ្មីៗនេះ មានការរៀបចំគួរ អោយទាក់ទាញចិត្តក្រៃលែង ។ នៅទីនោះ មានកន្លែងគេងប្រកបដោយផាសុកភាពហ៊ុមព័ទ្ធដោយរុក្ខជាតិបៃតងខ្ចី ខ្យល់អាកាសល្អបរិសុទ្ធ ពិសេសនោះ នៅក្បែរនឹងដងព្រែកដ៏



ស្រស់ស្អាតអាចថតរូបលេងកម្សាន្តយ៉ាងសប្បាយរីករាយ ។ កាន់តែពិសេសជាងនេះនោះខាងរីសតថែមទាំង មាន Free ចង្ក្រាន និងធ្យូងសម្រាប់អាំងសាច់ ហើយភ្ញៀវក៏អាចយកអាហារពីខាងក្រៅទៅញ៉ាំបានដែរ ។ចំពោះកន្លែងស្នាក់នៅវិញ មានជាប្រភេទបន្ទប់ និង វីឡា ។ សម្រាប់បន្ទប់គេងគ្រែ១ ក្នុងមួយយប់តម្លៃ៧០ដុល្លារ និងគ្រែ២ មួយយប់៨០ដុល្លារ ។ សម្រាប់វីឡា តម្លៃ ៣៥០ដុល្លារ ក្នុង១យប់ និងអាចគេងបាន១៤នាក់ ។ ចំពោះទីតាំងវិញស្ថិតនៅលើផ្លូវទឹកឈូ ឃុំអណ្តែង ខ្មែរ ភូមិអូរតូច ក្រុងកំពត ( តាមបណ្តោយផ្លូវទឹកឈូ ហួសស្ពានដែញ ២០០ម៉ែត្រ) ។ ប្រជាប្រិយ

# KhmerPost USA, LLC
## សារព័ត៌មានខ្មែរផុសសហរដ្ឋអាមេរិក



**អគ្គនាយក សុបិន្ត ពិន**
Soben Pin, Co-Founder|Publisher
Office: 978 677-7163 | Cell: 978-656-8141
Soben@khmerpostusa.com



**និពន្ធនាយកខ្មែរ** Khmer Editorial
និពន្ធនាយក ពិន សំខុន
Roger Samkhon Pin, Co-founder|Editor
978-942-8490 | pinsamkhon@gmail.com

**ផ្សាយពាណិជ្ជកម្ម សុបិន្ត ពិន**
Advertising Contact
Soben Pin
Cell: 979-656-8141
Soben@khmerpostusa.com

**អ្នកនិពន្ធកិត្តិយស** Staff Writer| Translator
Sokharath Koy | Khmerpostusa@gmail.com

**ច្នៃសោភ័ណ្ឌភាព** Design Artist
Heng Chhun Leng

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.
Follow us: Facebook | Twitter KhmerpostUSA



MILL CITY GROWS

ផ្សារចល័ត MOBILE Market

SNAP Supplemental Nutrition Assistance Program
កម្មវិធីជំនួយអាហារូបត្ថម្ភបន្ថែម

សូមរំពឹកការចុះថ្លៃរបស់យើង!
យើងទទួលយក SNAP, ប្រាក់សុទ្ធ, កាតឥណទាន, កាតឥណពន្ធ,
សំបុត្រលោះថ្លៃ ព្រឹទ្ធាវ៉ែយ និង WIC!

Healthy Incentives Program
Fresh. Canned. Dried. Frozen.
It's HIP to be healthy!
កម្មវិធីលើកទឹកចិត្តសុខភាពល្អ ស្រស់ៗ កំប៉ុងៗ ក្រៀមៗ កក

កាលវិភាគឆ្នាំ 2020

**អង្គារ**
ចំណតរថយន្ត Mill No. 5
កាត់ពីមុខ 30 Middlesex Street
10ព្រឹក- 1រសៀល

**ពុធ**
(ចាប់ផ្ដើមថ្ងៃទី 29 ខែកក្កដា)
Boys & Girls Club of Greater Lowell
657 Middlesex Street
3:3រសៀល - 5ល្ងាច

**ព្រហស្បតិ៍**
Lowell Senior Center Parking Lot
276 Broadway Street
10ព្រឹក- 1រសៀល

**សុក្រ**
Lucy Larcom Park 258
Merrimack Street
12ថ្ងៃត្រង់ - 3រសៀល

## គោលការណ៍ណែនាំសុវត្ថិភាពជំងឺ COVID-19

- អតិថិជន ត្រូវតែពាក់ប្រដាប់បាំងមុខ គ្រប់ពេលទាំងអស់ នៅពេលទិញឥវ៉ាន់
- អតិថិជន ត្រូវតែរក្សាចំងាយ 6ហ្វីត ឃ្លាតពីគ្នា គ្រប់ពេលទាំងអស់
- អតិថិជន ដែលមានរោគសញ្ញា រួមទាំងគ្រុន, ក្អក, ដកដង្ហើមផុតៗ, ឈឺសាច់ដុំ, ឬអស់កំឡាំង មិនត្រូវមកផ្សារឡើយ
- អតិថិជន ដែលត្រូវបានបញ្ជាឲ្យនៅដាច់ពីគេ ដោយអ្នកវិជ្ជាពេទ្យ មិនត្រូវមកផ្សារឡើយ
- តែសមាជិកម្នាក់នៃក្រុមគ្រួសារ គួរតែមកទិញឥវ៉ាន់នៅផ្សារ បើសិនអាចធ្វើបាន
- មិនអនុញ្ញាតឲ្យមានសត្វចិញ្ចឹម នៅឯផ្សារឡើយ
- ប្រើស្ថានីយ៍លាងដៃដែលបានផ្ដល់ឲ្យ នៅមុនពេលមកទិញឥវ៉ាន់នៅផ្សារ
- ថង់ដាក់ឥវ៉ាន់ដែលអាចប្រើជាសាថ្មី គឺមិនអនុញ្ញាតនៅពេលនេះឡើយ

ស្វែងយល់បន្ថែមទៀត អំពីការចែកចាយចម្ការរបស់យើងរាល់អាទិត្យ ទស្សនា MillCityGrows.org
**978-455-2620**



ASALEC CAMBODIA ASSOCIATION

## សមាគម"អាសេឡិច"មានអ្នកជួយ ធ្វើសំណុំរឿងជួយដល់អ្នកអត់ការធ្វើ

-ពាណិជ្ជករចង់បានប្រាក់ជំនួយជាប្រាក់កម្ចីរបស់រដ្ឋ និងជួយដល់អ្នកដែលមិនបានទទួលស៊ីមេលីស និងឯកសាររដ្ឋបាលផ្សេងៗទៀត ។
-មានសេវាផ្សេងទៀត ដូចជា: ថ្នាក់យកប័ណ្ណបើកបររថយន្ត ថ្នាក់បង្រៀនយកសញ្ជាតិអាមេរិកាំង មានសេវាសុំប័ណ្ណបើកម្ហូបអាហារ
-មានសេវាអន្តោប្រវេសន៍ទៀតផង
សូមទូរស័ព្ទមកសមាគម "អាសេឡិច" ទូរស័ព្ទលេខ 978-942-8490
អាស័យដ្ឋានលេខ: 325 Chelmford St. Lowell



ASALEC CAMBODIA ASSOCIATION

## សមាគមអតិថិជន្សន៍ អាមេរិកាំង-អាស៊ីអគ្នេយ៍

## ASALEC

(Association 501C3) 325 Chelmsfords St. Lowell MA 01851
Web: www.ASALEC.org Email: ASALEC.org@gmail.com

| | | |
|---|---|---|
| RogerSamkhon Pin | President | (978) 942 8490 |
| Rithy Sao | Vice President | (978) 654 1734 |
| Serey Em | Secretary | (978) 551 1193 |



## ការិយាល័យ មេធាវី ថំមាស ស្តាលីយ៉ាណូស

**Law Office of Thomas Stylianos Jr.**
**287 Appleton St. Lowell MA 01852**

- Immigration •អន្តោប្រវេសន៍
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ **978-459-5000 or 800-308-3766**
**www.thomasinlowell.com**

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare
Home Care Agency
Group Adults Foster Care Program

**បើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុម គ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។**

*At no Cost to you*

សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកដោយមិនគិតថ្លៃអ្នកនឹងត្រូវបានថែទាំដោយក្រុមបុគ្គលិកខ្មែរដែលមានវិជ្ជាជីវៈពី នើស (Nurse), Case Manager និង Home Health Aide បុគ្គលិកមានសណ្ដានចិត្តល្អ ទន់ភ្លន់ និងមានការគោរពទំនៀមទំលាប់ខ្មែរ ។ បំរើសេវាក្នុងតំបន់ Lowell, Lynn, Revere, Boston និងតំបន់ជុំវិញ





**ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**

- រស់នៅផ្ទះរដ្ឋ
- អាយុ ២២ ឆ្នាំឡើងទៅ
- មាសហែលស្ទង់ដា

**ផលប្រយោជន៍ទទួលបាន :**

- ការថែទាំផ្ទាល់ខ្លួនមួយ ទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីជើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក២៤ម៉ោង

**To be eligibled for GAFC you must:**

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**

To register, please contact:

Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

"អត្ថបទស្រាវជ្រាវប្រវត្តិសាស្ត្រ"

# ប្រវត្តិនៃសមាគមអ្នកសារព័ត៌មានខ្មែរ "ខេជីអេ"

## អវសាន្តនៃសមាគម KJA Khmer Journalists Association

(KJA = Khmer Journalist Association )

ដោយ ពិន សំខុន **តពីលេខមុន**

មានថ្មីដៃខាងសរសេរនឹង ដាក់ចំណងជើងគួរឱ្យចង់អានតែធ្វើការទស្សន៍ ទាយនឹងឱ្យយោបល់ច្រើនដោយមិនចាំបាច់ចេញទៅយកព័ត៌មានក៏បានដែរ... តែអ្នកអានចូល ចិត្តជំនាញរបៀបនោះណាស់ ដែលធ្វើឱ្យកាសែត លក់ដាច់ច្រើនច្បាប់ដោយអានកំសាន្តច្រើនជាងអានព័ត៌មាន ដូច្នោះបើមិនចាំបាច់មានការផ្សាយពាណិជ្ជកម្មច្រើនក៏រស់បានដែរ ។

នៅមានកាសែតសេដ្ឋកិច្ច, កាសែតអារីយធម៌កាសែត...។ ជាកាសែតធុនតូចរាប់សិបទៀតដែលទទួលការទ្រទ្រង់ពីគណបក្សប្រជាជនចេញផ្សាយ១ពាន់ឬ២ពាន់ច្បាប់ ដែលរស់បានដោយការគាំទ្រសេដ្ឋកិច្ចពីគណបក្សប្រជាជនសម្រាប់គេប្រើប្រាស់ជាសម្លេងឃោសនារបស់បក្ស ។ ជាទូទៅអ្នកសរសេរច្រើនប្រើវិធីជម្រឹតយកកម្រៃពីប្រជាជនសម្រាប់រស់បន្ថែម ។

ការបំបែកសាមគ្គីអ្នកគ្រប់គ្រងសមាគមអ្នកសារព័ត៌មាន ជាពីរ គឺ "សមាគមអ្នកសារព័ត៌មានខ្មែរ KJA» ហើយនឹងឪសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា LCJ» បានធ្វើឱ្យវិស័យព័ត៌មាននៅប្រទេសកម្ពុជា ចុះអូនថយជាខ្លាំង ដោយការផ្សព្វផ្សាយព័ត៌មានត្រូវរងដោយការគម្រៀមកំហែង តែពុំមានកម្លាំងការពារគ្រប់គ្រាន់, ពុំអាចអនុវត្តន៍នូវសេរីភាពនៃសារព័ត៌មានបាន, ការសរសេររបស់អ្នកកាសែត ក៏មិនបានបំរើសច្ចភាពនៃព័ត៌មានដោយអ្នកនយោបាយនៅពីក្រោយ...។ កាសែតតែ២គត់ ដែលបំរើព័ត៌មានត្រឹមត្រូវជាគំរូនៃសារព័ត៌មានឯទៀតៗក្នុងស្រុក តែក៏មានសម្ពាតពីរដ្ឋាភិបាលខ្លែងណាស់ដែរ នាពេលនោះ ។



ពិន សំខុន



តាត លីហុក

ជាសំណាងល្អមួយដែរ ដែលនៅឆ្នាំ១៩៩៦ KJA បានជម្រុញឱ្យលោក Bernard Krisher& Mike Fauler ជួយបង្កើតបានជាសាលាវិជ្ជាជីវៈសារព័ត៌មានមួយនៅសកលវិទ្យាល័យភ្នំពេញជាមួយនឹងថវិការ Asia Foundation American បង្រៀនដោយលោកគ្រូ សុខ ឃៀង នឹងសាលាវិជ្ជាជីវសារព័ត៌មានមួយទៀត ជាជំនួយមកអូស្ត្រាលី តាមរយៈអ្នកស្រី Susan AitKin បង្កើតនៅក្នុងបរិវេណក្រសួងព័ត៌មាន បង្រៀនដោយលោកគ្រូ បរិសុទ្ធ ។សាលារៀនវិជ្ជាជីវទាំងពីរនេះ បានដំណើរការដោយសុខសាន្តជាច្រើនឆ្នាំ ដោយសារការមិនលូកដៃបញ្ចេញមតិពីរឿងនយោបាយ ហើយក៏ក្លាយជាអង្គការឯករាជ្យនៅក្នុងការគ្រប់គ្រងរបស់រដ្ឋាភិបាល ។

ឆ្នាំ១៩៩៧ ខែកក្កដា លោក ហ៊ុន សែន នឹងគណបក្សប្រជាជនផ្តើមវាយប្រហាផ្តាច់ព្រ័តលើគណបក្សហ្វ៊ុនស៊ិនប៉ិច នឹងគណបក្សប្រឆាំងទាំងអស់ដោយការប្រើកងទ័ពជាតិនឹងនគរបាលជាតិបណ្តាលឱ្យការសម្លាប់នឹងចាប់ខ្លួន អ្នកដែលនៅក្នុង ចលនាប្រឆាំង នឹងអំណាច លោក ហ៊ុន សែន ជាច្រើនរយនាក់ ។ រដ្ឋប្រហាររបស់នាយករដ្ឋមន្ត្រីទី២ ហ៊ុន សែន ទៅលើនាយករដ្ឋមន្ត្រីទី១ បានប្រព្រឹត្តទៅប្រកបដោយជោគជ័យ ហើយបណ្តេបបាននាយករដ្ឋមន្ត្រីទី១ ជំនួសម្នាក់គឺលោក អ៊ឹង ហួត ប៉ុន្តែនៅអ.ស.ប.ឯណោះគេបានព្យួរ "អាសនៈកម្ពុជា"រួចបាត់ទៅហើយដែរ ។

ពិន សំខុន ជាប្រធានសមាគមKJA ក៏មានឈ្មោះក្នុងបញ្ជីខ្មៅរបស់ក្រុមរដ្ឋប្រហារ ក៏បានត្រូវសមាជិកអ.ស.ប. នៅកម្ពុជារកឃើញ ហើយក៏បញ្ជូនចេញទៅបាងកកដោយអង្គការលីកាដូនឹងអាដហុកជាបន្ទាន់ ដើម្បីរក្សាសុវត្ថិភាព ប៉ុន្តែពិន សំខុន ពុំបានត្រឡប់មកភ្នំពេញវិញជារៀងរហូត ។ ខេជីអេ នៅជាមួយនឹងសហប្រធាន តាត លីហុក ក៏មិនបានរស់រានមានជីវិតយូរដែរ ។ ចប់បរិបូរណ៍






# ពេលវេលាគឺជិតអស់ហើយ។ សូមបំពេញជំរឿនឆ្នាំ-2020នៅថ្ងៃនេះ។

ចម្លើយរបស់អ្នកជួយ ប្រាប់ពី កន្លែងដែលថវិកាជំនួយរាប់ពាន់លានដុល្លារអាមេរិកនឹងត្រូវទៅសម្រាប់ជួយដល់គ្លីនិកសុខភាព សេវាសង្គ្រោះបន្ទាន់ និង វិស័យអប់រំជារៀងរាល់ឆ្នាំ សម្រាប់រយៈពេលដប់ឆ្នាំខាងមុខទៀតនេះ។ ប្រសិនបើអ្នកមិនទាន់បានធ្វើការបំពេញជំរឿនរបស់អ្នកទេអ្នកធ្វើការខាងជំរឿននឹងទៅជួយអ្នកដោយពួកគេពាក់ម៉ាស់និងធ្វើតាមការណែនាំក្នុងមូលដ្ឋានដើម្បីធានាសុវត្ថិភាពរបស់អ្នករាល់គ្នា។ **អ្នកនៅមានពេលដើម្បីបំពេញជំរឿនតាមអ៊ីនធឺណិតឬតាមសំបុត្របាន។ស្វែងយល់ពីរបៀបបំពេញជំរឿននេះនៅគេហទំព័រ 2020CENSUS.GOV/km**

Shape your future
START HERE >

United States® Census 2020

**2020CENSUS.GOV/km**

ឧបត្ថម្ភដោយ ក្រសួងជំរឿនប្រជាជនសហរដ្ឋអាមេរិក (U.S. Census Bureau)